# «ប្រាំពីរ» និង «ប្រាំពិល»

*នៅក្នុងភាសាខ្មែរ របាប់លេខខ្ទង់រាយដែលមានចំនួនលើសពីប្រាំ ត្រូវបូកថែមនឹងមួយ ពីរ បី និងបួន ទៅជាប្រាំមួយ ប្រាំពីរ ប្រាំបី និងប្រាំបួន។ ក្នុងចំណោមចំនួននេះ យើងសង្កេតឃើញថាពាក្យ «ប្រាំពីរ» ជាទូទៅ ប្រជាជនខ្មែរនិយមនិយាយជា «ប្រាំពិល»? តើមនុស្សខ្មែរទើបតែនិយាយបែបនេះនាពេលថ្មីៗ ឬយូរលង់មកហើយ? តើការនិយាយពាក្យ «ប្រាំពីរ» ជា «ប្រាំពិល» បណ្ដាលមកពីកត្តាអ្វី?*

*នៅទីនេះ យើងរំលឹកអំពីពាក្យនេះតាំងពីសម័យមុនអង្គរហូតមក។ យោងតាមបណ្ដាសិលាចារឹកនាសម័យមុនអង្គរ គេពុំទាន់ប្រទះសំណេរបុរាណនៃពាក្យ «ប្រាំពីរ» នេះនៅឡើយទេ ឃើញមានប្រើតែសញ្ញាលេខប្រាំពីរប៉ុណ្ណោះ។ យ៉ាងនេះក្ដីពាក្យ «ពីរ» នៅសម័យមុនអង្គរ មានសំណេរជា៖* ***វេរ៑*** *(K.២២ បន្ទាត់ទី២២ គ.ស.៦-៧; K.៧៦ បន្ទាត់ទី៩ គ.ស.៦-៧; K.១ បន្ទាត់ទី១៥ គ.ស.៦-៨; K.៦៦៤ បន្ទាត់ទី១៤ គ.ស.៦-៨; K.៦៨៩ក បន្ទាត់ទី១៥ គ.ស.៦-៨; K.៩០៣ខ បន្ទាត់ទី៣និង៧ គ.ស.៦-៨)* ***វេរ*** *(K.១៥៤ក បន្ទាត់ទី៦ ឆ្នាំ៧៣៤គ.ស.; K.៥១ បន្ទាត់ទី១៦ គ.ស.៦-៧; K.៧១១ បន្ទាត់ទី១០ គ.ស.៦-៧; K.១ បន្ទាត់ទី២០ គ.ស.៦-៨) និង* ***ពេរ៑*** *(K.៣៨៨គ បន្ទាត់ទី៣និង៧ គ.ស.៦-៧)។[១] ចំណែកឯពាក្យ «ប្រាំ» នៅសម័យមុនអង្គរ មានសំណេរតែម្យ៉ាងគត់គឺ* ***ប្រំ***។ *ដូច្នេះពាក្យ «ប្រាំពីរ» នៅសម័យមុនអង្គរទំនងជាមានសំណេរជា៖* ***ប្រំវេរ៑ ប្រំវេរ*** *និង* ***ប្រំពេរ៑***។

*មកដល់សម័យអង្គរ បើទោះបីជាពាក្យ «ពីរ» មានសំណេរជា៖* ***វ្យរ៑ វ្យរ ព្យរ៑*** *និង* ***ពេរ៑*** *ក៏ដោយ ក៏សំណេរពាក្យ «ប្រាំពីរ» នៅក្នុងសិលាចារឹក គេឃើញសរសេរជា «ប្រំវ្យល៑» ឬ «ប្រំវ្យល» ទៅវិញ និងឃើញមានសំណេរតែមួយបែបនេះប៉ុណ្ណោះ។ សំណារ «ប្រំវ្យល៑» និង «ប្រំវ្យល» យ៉ាងហោចណាស់លេចឡើងចំនួន៤៨ដង ក្នុងសិលាចារឹកសម័យអង្គរ ដែលក្នុងចំណោមនោះ សំណេរចាស់ជាងគេ លេចឡើងនៅក្នុងរវាងពាក់កណ្ដាលឬចុង*

[១] Jenner 2009: 465។

*អត្ថបទដោយ៖ ហ៊ុន ឈុនតេង*

ស.វ.ទី១០។ លុះមកដល់សម័យកណ្ដាល គេឃើញមានសំណេរពាក្យ «ប្រាំពីរ» ច្រើនរបៀបដាៈ **ប្រាំពីរ** (ជួបតែម្ដងគត់ក្នុងសិលាចារឹក K.២៧ បន្ទាត់ទី២៣ ឆ្នាំ១៥៨៦) **ប្រាំម្ពិល** (IMA៣៨ បន្ទាត់ទី១៧ ឆ្នាំ១៧០៤) **ប្រំពិល** (IMA២៤ បន្ទាត់ទី១ ឆ្នាំ១៦៤៣) **ប្រាំព្យិល** (IMA៤២ បន្ទាត់ទី៤ ឆ្នាំ១៥៩៩) **ប្រាមពិល** (IMA៤គ បន្ទាត់ទី៣ ឆ្នាំ១៥៩៩; (IMA១៤ បន្ទាត់ទី១០ ឆ្នាំ១៦៣១) និង **ប្រាំពិល** (IMA៨ បន្ទាត់ទី១៩ ឆ្នាំ១៦២៦)។[២] ទោះបីជាមានសំណេរផ្សេងៗគ្នា យើងឃើញថានៅសម័យកណ្ដាលមានប្រើពាក្យនេះពីររបៀបគឺ «ប្រាំពីរ» និង «ប្រាំពិល»។

ដូចបានលើកបង្ហាញមកហើយ ពាក្យ «ប្រាំពីរ» គឺជាការងាយយល់បំផុត ដ្បិតកើតឡើងពីការផ្សំពាក្យ «ប្រាំ» និង «ពីរ» ប៉ុន្តែការអានជា «ប្រាំពិល» អាចជាការលំបាកយល់បន្តិច បើទោះបីជាខ្មែរយើងនិយាយរត់មាត់មកហើយក្ដី។ ចំណុចនេះ លុះណាតែស្វែងយល់តាមទស្សនៈភាសាសាស្ត្រ ទើបនឹងយល់បាន។ សូររបស់ព្យញ្ជនៈ «រ» និង «ល» មានលក្ខណៈជាសូរលំហូរឬសូរបង្វិល ដ្បិតសូរព្យញ្ជនៈទាំងពីរនេះនៅបន្ទឺ សូរដែលរត់ចេញពីសួត ស្ទើរតែមិនត្រូវជុសនឹងផ្ទៃគុហាមាត់ អណ្ដាត ធ្មេញ ឡើយ ហាក់បីដូចជាមានលំហូរ។[៣] បើនិយាយឱ្យកាន់តែសាមញ្ញ សូរព្យញ្ជនៈពីរនេះខុសគ្នាត្រង់សូរព្យញ្ជនៈ «រ» មានការញ័រឬរលាស់ចុងអណ្ដាត ចំណែកឯសូរព្យញ្ជនៈ «ល» មិនមានការញ័រឬរលាស់ចុងអណ្ដាតឡើយ។ ដូច្នេះ ប្រសិនបើបញ្ចេញសំឡេងព្យញ្ជនៈ «រ» ដោយមិនរលាស់ចុងអណ្ដាត នោះនឹងក្លាយជាសូរព្យញ្ជនៈ «ល» ពុំខាន។ ករណីបែបនេះហើយ ទើបនាំឱ្យមានបម្រែបម្រួលសូរព្យញ្ជនៈ «រ» ជា «ល» នៅក្នុងភាសាខ្មែរ ទាំងសូរដើមព្យាង្គ ទាំងសូរចុងព្យាង្គ។ យើងអាចពិនិត្យលើពាក្យ «រកេតរកូត រគង រងោ ខ្នុរ កណ្ដុរ សម្បុរ អុរ ពុរ ខ្ពុរ...» មានអ្នកនិយាយទៅជា «ល្កេតល្កូត ល្គង ល្ងោ ខ្នុល កណ្ដុល សម្បុល អុល ពុល ខ្ពុរ...»។ ត្រង់នេះ ពុំគួរប្រទាំ្បរវាងអក្ខរាវិរុទ្ធរបស់ពាក្យ និងសូរដែលអ្នកស្រុកបន្ទឺនោះឡើយ។ បើ

---

[២] Jenner 2011: 210។

[៣] ក្រុមប្រឹក្សាជាតិភាសាខ្មែរ ២០១៣: ៥៥។

មើលឱ្យឆ្ងាយជាងនេះបន្តិច ជាតិសាសន៍ខ្លះទៀតមិនអាចបញ្ចេញសំឡេង «រ» បានទេ ពល់សំឡេង «រ» តែងបន្ទឺសូរជា «ល» ទៅវិញ ដោយគេពុំអាចរលាស់ចុងអណ្ដាតបាន។ ដូច្នេះបាតុភូតនេះ មិនមែនកើតឡើងតែក្នុងភាសាខ្មែរប៉ុណ្ណោះទេ។

ជាសរុបមក ពាក្យ «ប្រាំពីរ» ដែលខ្មែរយើងនិយមនិយាយជា «ប្រាំពិល» នោះ ពុំមែនទើបតែកើតឡើងថ្មីៗនោះទេ ដូចមានភស្តុតាងក្នុងសិលាចារឹកបញ្ជាក់ស្រាប់។ ការនិយាយពាក្យ «ប្រាំពីរ» ជា «ប្រាំពិល» នេះ កើតឡើងដោយការប្រែប្រួលសូរព្យញ្ជនៈចុងព្យាង្គ «រ» ទៅជា «ល» ដូចមានឧទាហរណ៍ពាក្យដទៃទៀត ដែលបានលើកបង្ហាញខាងលើមកស្រាប់។ ករណីប្រែប្រួលនេះ កើតឡើងចំពោះតែពាក្យ «ប្រាំពីរ» តែមួយប៉ុណ្ណោះ មិនឃើញមានកើតឡើងចំពោះពាក្យ «ដប់ពីរ ម្ភៃពីរ សាមពីរ...» នោះឡើយ។ ចំណុចនេះជាតឹកតាងមួយបង្ហាញថា ការបញ្ចេញសូរសំឡេងខុសពីសំណេរ ឬខុសប្លែកពីតំបន់មួយទៅតំបន់មួយ អាចកើតឡើយដោយសារកត្តាបម្រែបម្រួលដែលមានដានលក្ខណៈជាប្រវត្តិសាស្ត្រដ៏យូរអង្វែង។ ការមើលដោយចង្អៀតចង្អល់ចំពោះភាសា ដោយប្រញាប់ប្រញាល់ការនិយាយបែបនេះខុស បែបនោះខុស ដោយមិនបានពិនិត្យលើប្រវត្តិភាសាខ្មែរដែលមានជាយូរអង្វែងមកហើយនោះ នឹងអាចនាំឱ្យបាត់ដានដែលបន្សល់មកពីបុរាណផងដែរ។

## ឯកសារយោង


Jenner, P. N.
2009. *A dictionary of Angkorian Khmer*. Pacific linguistics, Research school of Pacific and Asian studies, the Australian national University.

Jenner, P. N.
2011. *A dictionary of Middle Khmer*. Pacific linguistics, Research School of Pacific and Asian Studies, The Australian National University.

ក្រុមប្រឹក្សាជាតិភាសាខ្មែរ
២០១៣. សទ្ទានុក្រមភាសាវិទ្យានិងអក្សរសិល្ប៍ ខ្មែរ-អង់គ្លេស-បារាំង។


អត្ថបទដោយៈ ហ៊ុន ឈុនតេង

# បញ្ជីរូបភាព



ពាក្យ «ប្រំវ្យល» នៅក្នុងសិលាចារឹកទួលអង្គក្រសាំងធ្នារ K.១៤៣៩ (រូបថត៖ ហ៊ុន ឈុនតេង)



ពាក្យ «ប្រំវ្យល» នៅក្នុសិលាចារឹកប្រាសាទបាសែត K.២០៥ (រូបថត៖ សមុច្ច័យសារមន្ទីរជាតិ)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង